**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០៤៥ ប្រក

ថ្ងៃ អង្គារ ៧រោច ខែ ស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

# ប្រកាស

## ស្តីពី

## ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មភោជនីយដ្ឋានទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

- បានឃើញប្រកាសលេខ ០៨៤ ប្រក ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់អនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១ ៈ**

ប្រកាសនេះ មានគោលបំណងធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងលើកកម្ពស់សុវត្ថិភាពទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ ៈ**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មរមណីយដ្ឋានទេសចរណ៍។

**ប្រការ៣ ៈ**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់រមណីយដ្ឋានទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ៈ**

លក្ខខណ្ឌសម្រាប់វាយតម្លៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់រមណីយដ្ឋានទេសចរណ៍ក្នុងដំណាក់កាលការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ១នៃប្រកាសនេះ។

**ប្រការ៥ ៈ**

រមណីយដ្ឋានទេសចរណ៍ដែលបំពេញបានលក្ខខណ្ឌដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១នៃប្រកាសនេះ នឹងទទួលបានវិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់ជារមណីយដ្ឋានទេសចរណ៍ដែលមានសុវត្ថិភាពក្នុងការទប់ស្កាត់ការរីករាលដាលនៃកូវីដ-១៩ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ៦ ៈ**

វិធានសុវត្ថិភាពទេសចរណ៍នេះ ត្រូវបានដាក់ឱ្យអនុវត្តជាកាតព្វកិច្ច និងជាលក្ខខណ្ឌបន្ថែមក្នុងការស្នើសុំថ្មីឬបន្តអាជ្ញាបណ្ណទេសចរណ៍ ឬការស្នើសុំប្រកបសកម្មភាពទេសចរណ៍នៅគ្រប់រមណីយដ្ឋានទេសចរណ៍។

គ្រប់អាជីវកម្មរមណីយដ្ឋានទាំងអស់ដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍នេះនឹងក្លាយជាកម្មវត្ថុនៃការព្យួរអាជ្ញាបណ្ណ ឬការផ្អាកសកម្មភាពទេសចរណ៍ជាបន្ទាន់ ស្របតាមមាត្រា៤៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ៧ ៈ**

វិធានសុវត្ថិភាពទេសចរណ៍សម្រាប់រមណីយដ្ឋានទេសចរណ៍នេះ ត្រូវបានដាក់ឱ្យអនុវត្តក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩ ហើយអាចនឹងបន្តក្នុងដំណាក់កាលបន្តទៀតតាមការចាំបាច់។

**ប្រការ៨ ._**

ប្រកាសលេខ ០៨៤ ប្រ.ក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មមណីយដ្ឋានទេសចរណ៍ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ ._**

នាយកខុទ្ទកាល័យ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## លក្ខខណ្ឌវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់ អាជីវកម្មរមណីយដ្ឋានទេសចរណ៍

| ល.រ | លក្ខណៈវិនិច្ឆ័យ (មួយចំណុចស្មើនឹងមួយពិន្ទុ) | ឯកសារវាយតម្លៃ | ចាំបាច់ | បំពេញ |
|---|---|---|---|---|
| **១. ការធានាសុវត្ថិភាពភ្ញៀវទេសចរ** | | | | |
| ១.១. | - ត្រូវអនុវត្តឲ្យបានយ៉ាងខ្ជាប់ខ្ជួននូវវិធានការទាំងឡាយដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.២. | - ត្រូវអនុវត្តឲ្យបានម៉ត់ចត់វិធានការ "៣ **ការពារ**" គឺពាក់ម៉ាស់ លាងដៃ និងរក្សាគម្លាតសុវត្ថិភាព និងវិធានការ "៣ កុំ" គឺកុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំចូលទៅកន្លែងដែលបិទជិតឈឹង និងកុំប៉ះពាល់គ្នា"។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.៣. | - ត្រូវរៀបចំច្រកទ្វារចូលរមណីយដ្ឋានឲ្យបានសមរម្យដើម្បីធ្វើសម្រង់ព័ត៌មានភ្ញៀវទេសចរទាំងអស់ដែលចូលកម្សាន្តក្នុងរមណីយដ្ឋាន ជាពិសេសកត់ត្រាអាសយដ្ឋាន និងលេខទំនាក់ទំនងភ្ញៀវទេសចរទាំងអស់ឲ្យបានម៉ត់ចត់។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.៤. | - ត្រូវចុះឈ្មោះបង្កើតនិងប្រើប្រាស់ប្រព័ន្ធQRCode ទប់ស្កាត់កូវីដ-១៩ និងតម្រូវឲ្យភ្ញៀវទេសចរត្រូវតែស្កេនជាដាច់ខាតមុនចូលទៅក្នុងកន្លែងរបស់ខ្លួន។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.៥. | - ត្រូវរៀបចំនូវការត្រួតពិនិត្យកម្ដៅគ្រប់ភ្ញៀវទេសចរដែលត្រូវចូលទៅកម្សាន្តនៅតាមរមណីយដ្ឋានទេសចរណ៍។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.៦. | - ត្រូវរៀបចំឲ្យមានការបាញ់អាល់កុលសម្លាប់មេរោគមុននឹងចូលកម្សាន្តក្នុងរមណីយដ្ឋាន។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.៧. | - ភ្ញៀវទេសចរតម្រូវឲ្យប្រើប្រាស់ម៉ាស់ឲ្យបានជាប្រចាំ។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.៨. | - ត្រូវណែនាំឲ្យភ្ញៀវទេសចរលាងសំអាតដៃជាប្រចាំ និងរាល់ពេលដែលចាប់កាន់វត្ថុថ្មី។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.៩. | - ត្រូវរៀបចំឲ្យមានបុគ្គលិកប្រចាំការដើម្បីណែនាំភ្ញៀវទេសចរឱ្យអនុវត្តតាមវិធានសុវត្ថិភាពក្នុងការ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |

| | | | | |
|---|---|---|---|---|
| | ទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ មុនពេលចូលកម្សាន្តក្នុងរមណីយដ្ឋាន។ | | | |
| ១.១០. | - ត្រូវបញ្ចៀសការជួបជុំជាក្រុមធំ និងត្រូវរក្សាគំលាតសុវត្ថិភាពឲ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងសុខាភិបាល។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ១.១១. | - ត្រូវជំរុញលើកទឹកចិត្តភ្ញៀវទេសចរឲ្យទៅលំហែកម្សាន្តជាមួយធម្មជាតិ និងសក្តានុពលដែលមានក្នុងគោលដៅទេសចរណ៍ខាងលើ ដើម្បីបញ្ចៀសការជួបជុំទ្រង់ទ្រាយធំ។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | | ✓ |
| ១.១២. | - ខិតខំរៀបចំឲ្យមានលំហបើកទូលាយឲ្យបានច្រើនកន្លែងនៅក្នុងរមណីយដ្ឋាន។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | | ✓ |
| **២. ការរៀបចំរមណីយដ្ឋានទេសចរណ៍** | | | | |
| ២.១. | - ត្រូវកំណត់អំពីសមត្ថភាពផ្ទុកអតិបរមា (Carrying Capacity) ដែលរមណីយដ្ឋានទេសចរណ៍អាចទទួលភ្ញៀវទេសចរបានក្នុងមួយពេល។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ២.២. | - ត្រូវកំណត់ទីតាំងក្នុងរមណីយដ្ឋានទេសចរណ៍ដែលភ្ញៀវទេសចរ អាចប្រើប្រាស់រួមគ្នាបាន។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ២.៣. | - ត្រូវរៀបចំគំនូសបែងចែកគន្លងធ្វើដំណើររបស់ភ្ញៀវទេសចរនៅតាមទីតាំងដែលចាំបាច់ដើម្បីបញ្ចៀសការកកកុញ ឬការជួបជុំមនុស្សច្រើនជាយថាហេតុ។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ២.៤. | - ត្រូវលើកស្លាកសញ្ញាស្តីពីគ្រោះថ្នាក់ និងវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ ពិសេសវិធានការ "**៣ ការពារ** និង **៣ កុំ**" នៅតាមទីតាំងសំខាន់ៗក្នុងរមណីយដ្ឋាន។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ២.៥. | - ត្រូវបិទផ្សាយបណ្ណព័ត៌មាន និងសេចក្តីប្រកាសនានាអំពីវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួងទេសចរណ៍ ក្នុងការទប់ស្កាត់ការរីករាលនៃជំងឺកូវីដ១៩។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ២.៦. | - ត្រូវរៀបចំឲ្យមានអាល់កុលបាញ់សម្លាប់មេរោគ និងសម្រាប់លាងដៃឲ្យបានគ្រប់គ្រាន់ និងគ្រប់ទីកន្លែងដែលចាំបាច់។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |

| | | | | |
|---|---|---|---|---|
| ២.៧. | - ត្រូវធ្វើការសំអាតឲ្យបានជាប្រចាំបន្ទប់ទឹក បរិវេណ និងទីតាំងនានា ដែលភ្ញៀវទេសចរបានប៉ះពាល់។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ២.៨. | - រមណីយដ្ឋានទេសចរណ៍ ដែលផ្តល់សេវាស្នាក់នៅម្ហូបអាហារ និងសេវាផ្សេងៗទៀតជូនភ្ញៀវទេសចរត្រូវអនុវត្តតាមវិធានសុវត្ថិភាពទេសចរណ៍នៃសេវាទាំងនោះដែលដាក់ចេញដោយក្រសួងទេសចរណ៍។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ២.៩. | - ខិតខំអនុវត្តការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ក្នុង "គន្លងប្រក្រតីភាពថ្មី (New Normal Protocol)" | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | | ✓ |
| ២.១០. | - ជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្នុងដំណើរការអាជីវកម្ម និងការប្រកបសកម្មភាពនានាក្នុងរមណីយដ្ឋាន ដូចជាការបំពាក់កាមេរ៉ាសុវត្ថិភាព ការបញ្ជាទិញនិងប្រើប្រាស់សេវាផ្សេងៗក្នុងរមណីយដ្ឋាន និងការទូទាត់ប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាជាដើម។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | | ✓ |
| ២.១១. | - រមណីយដ្ឋានត្រូវចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តនូវគោលនយោបាយនានាក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពជាក់ស្តែង។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ២.១២. | - ជម្រុញការរៀបចំកម្មវិធីលើកទឹកចិត្តភ្ញៀវទេសចរដែលបានចាក់វ៉ាក់សាំងគ្រប់ចំនួនដូសតាមការណែនាំរបស់ក្រសួងសុខាភិបាល។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | | ✓ |
| **៣. ការគ្រប់គ្រង និងចាត់ចែងបុគ្គលិក** | | | | |
| ៣.១. | - បុគ្គលិកបម្រើការក្នុងរមណីយដ្ឋានត្រូវទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩គ្រប់ចំនួនដូសតាមការណែនាំរបស់ក្រសួងសុខាភិបាល។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ៣.២. | - បុគ្គលិកបម្រើការក្នុងរមណីយដ្ឋាន ត្រូវទទួលបានការបណ្តុះបណ្តាលអំពីសេវាកម្មទេសចរណ៍ និងការធ្វើបដិសណ្ឋារកិច្ចប្រកបដោយស្តង់ដា។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |

| | | | | |
|---|---|---|---|---|
| ៣.៣. | - បុគ្គលិកបម្រើការក្នុងរមណីយដ្ឋាន ត្រូវទទួលបានការបណ្តុះបណ្តាលអំពីវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩នេះ។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ៣.៤. | - បុគ្គលិកបម្រើការក្នុងរមណីយដ្ឋាន ត្រូវអនុវត្តជាគំរូ និងជាប្រចាំក្នុងពេលបំពេញការងារនូវរាល់វិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ៣.៥. | - គ្រប់បុគ្គលិកបម្រើការក្នុងរមណីយដ្ឋាន ត្រូវពន្យល់ណែនាំអំពីវិធានការទប់ស្កាត់ជំងឺកូវីដ-១៩នេះ ដល់ភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធ និងត្រូវឲ្យភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធចូលរួមអនុវត្តជាកាតព្វកិច្ច។ ក្នុងករណីភ្ញៀវទេសចរ និងដៃគូពាក់ព័ន្ធពុំអនុវត្តតាមត្រូវរាយការណ៍ទៅគណៈគ្រប់គ្រងរមណីយដ្ឋាន ដើម្បីមានវិធានការបន្ត។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | ✓ | |
| ៣.៦. | - រមណីយដ្ឋានត្រូវលើកទឹកចិត្តឲ្យបុគ្គលិកទាំងអស់រាយការណ៍អំពីស្ថានភាពសុខភាពរបស់ខ្លួនជាប្រចាំដើម្បីបញ្ចៀសហានិភ័យនៃការចំលងជំងឺកូវីដ-១៩ ជាយថាហេតុ។ | រូបភាព និងឯកសារបញ្ជាក់ពីការអនុវត្ត | | ✓ |
| **សរុប (ពិន្ទុ)** | | | **២៤០** | **៦០** |

វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍មាន **៣០ ចំណុច** ត្រូវវាយតម្លៃស្មើនឹង **៣០០ ពិន្ទុ**។

ក្នុងន័យនេះ អាជីវកម្មដែលចាត់ទុកជាអនុវត្តត្រឹមត្រូវតាម ***"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់រមណីយដ្ឋានទេសចរណ៍"*** នឹងទទួលបានលិខិតបញ្ជាក់ទទួលស្គាល់ជារមណីយដ្ឋានទេសចរណ៍ លុះត្រាតែៈ

- អាជីវកម្មទទួលបានពិន្ទុចាប់ពី ៩០% ឡើងទៅនៃពិន្ទុសរុប ហើយ
- អាជីវកម្មបំពេញបានគ្រប់ចំណុចតម្រូវចាំបាច់ទាំង ២៤ ចំណុច។

លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេលអតិបរមា ០១ឆ្នាំ។ លិខិតបញ្ជាក់នេះនឹងចាប់គិតសុពលភាពពីកាលបរិច្ឆេទសម្រេចផ្តល់លិខិតបញ្ជាក់ជូន រហូតដល់ការបញ្ចប់សុពលភាពនៅកាលបរិច្ឆេទសុពលភាពអាជ្ញាបណ្ណទេសចរណ៍ក្នុងឆ្នាំអនុវត្តតែមួយនោះ។

អាជីវកម្មដែលធ្លាប់ទទួលបានលិខិតបញ្ជាក់រួចហើយ នោះការបន្តស្នើសុំវាយតម្លៃដើម្បីទទួលបានលិខិតបញ្ជាក់ឆ្នាំអនុវត្តបន្ត គឺចាប់រាប់នៅពេលស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬលិខិតអនុញ្ញាតប្រកបសកម្មភាពទេសចរណ៍។

# ឧបសម្ព័ន្ធទី២

## គំរូវិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់រមណីយដ្ឋានទេសចរណ៍ដែលមានសុវត្ថិភាពក្នុងការទប់ស្កាត់ការរីករាលដាលនៃកូវីដ-១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Logo
រដ្ឋបាលរាជធានី-ខេត្ត

រដ្ឋបាលរាជធានី-ខេត្ត
លេខ:........................

# លិខិតបញ្ជាក់

ជូន

អាជីវកម្មឈ្មោះ..................................................................................................

អក្សរឡាតាំង......................................................................................................

ដែលបានអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍.................

សុពលភាពគិតចាប់ពីថ្ងៃទី....................................ដល់ថ្ងៃទី....................................

ទទួលបានពិន្ទុ.................

FIGHT AGAINST
COVID-19
SAFE RESORT

ថ្ងៃទី............................ខែ..................ស័ក ព.ស.២៥.........
.................... ថ្ងៃទី...........ខែ................ឆ្នាំ......................
**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

*សម្គាល់: លិខិតបញ្ជាក់នេះនឹងត្រូវបានប្រើប្រាស់សម្រាប់ភ្ជាប់ជាមួយក្នុងការចេញអាជ្ញាបណ្ណទេសចរណ៍ថ្មី និងបន្ត។